# ២- សេចក្តីសំរេច

## សេចក្តីសំរេច លេខ ៤៦ សសរ
## ស្តីពីការបង្កើតក្រុមការងារ
## សំរាប់រៀបចំ អនុក្រឹត្យ ច្បាប់ ស្តីពី ផ្សារ សញ្ញាប័ណ្ណ និងមូលប័ត្រ នៅកម្ពុជា

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារមួយសំរាប់រៀបចំអនុក្រឹត្យ ច្បាប់ ស្តីពី ផ្សារ សញ្ញាប័ណ្ណ និងមូលប័ត្រនៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម មិត ស៊ាងលីម | អនុប្រធានក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ | ប្រធាន |
| ២-ឯកឧត្តម អ៊ុំ វុទ្ធី | សមាជិក ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ | សមាជិក |
| ៣-លោក ឡុញ ងៃ | អគ្គនាយករង ធនាគារជាតិកម្ពុជា | សមាជិក |
| ៤-លោក លី ផាណ្ណា | ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥-លោក ម៉ី ទ៊ាន់ | អនុប្រធាននាយកដ្ឋានឧស្សាហកម្ម-ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២ :** ក្រុមការងារនេះមានភារកិច្ច :

-សិក្សាស្រាវជ្រាវរៀបចំ ធ្វើសេចក្តីព្រាង អនុក្រឹត្យ និងច្បាប់ ស្តីអំពី ផ្សារ សញ្ញាប័ណ្ណ និងមូលប័ត្រនៅកម្ពុជា

-ទំនាក់ទំនងជាមួយស្ថាប័នរាជរដ្ឋាភិបាល និងផ្នែកឯកជនដែលពាក់ព័ន្ធដើម្បីចូលរួមពិគ្រោះផ្លាស់ប្តូរយោបល់ និងបទពិសោធក្នុងការកសាងច្បាប់ ស្តីអំពីផ្សារ សញ្ញាប័ណ្ណ និងមូលប័ត្រឲ្យមានប្រសិទ្ធភាព

-ទំនាក់ទំនងជាមួយអង្គការអន្តរជាតិ ដើម្បីស្វែងរកជំនួយផ្តល់អោយដំណើរការរបស់ក្រុមការងារ និងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសជំនាញដល់មន្ត្រីជំនាញ

-ធ្វើរបាយការណ៍ពីលទ្ធផលការងារជាប្រចាំខែ ត្រីមាស ជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣ :** សមាជិកគណៈកម្មាធិការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គទេសាភិបាលធនាគារជាតិកម្ពុជា ប្រធាន និងសមាជិកក្រុមការងារដែលបានរាយនាមក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## សេចក្តីសំរេច លេខ ៤៧ សសរ
## ស្តីពីការបង្កើតក្រុមការងារ
## ចំរុះមួយ ដើម្បីប្រជុំដោះស្រាយ លើលក្ខខណ្ឌសេសសល់
## ក្នុងការបំពេញអោយចប់ នូវទំរង់បែបបទនៃគំរោងការ
## សាងសង់រោងចក្រអគ្គីសនី C4 របស់ក្រុមហ៊ុន Cambodia Power

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែង

-បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងសេចក្តីជូនដំណឹងលេខ ៩៥៨ សជណ.ផសរ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ២០០០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមតំរូវការចាំបាច់